# COVID-19 Report from RHCP

4th Edition, April 2020

Situation Report (as of April 20, 2020)
Olmsted County: 197 cases
Minnesota: 2,470 cases
United States: 746,625 cases
(Reference: MN Department of Health, CDC)

បញ្ឈប់ការរាលដាល
ប្រើក្រណាត់រុំមខពេលនៅកន្លែងសាធារណៈ
យកដៃបទមាត់ពេលក្អកឬកណ្ដាស់។
លាងដៃជាមួយសាប៊ូនិងទឹកឬប្រើអាលកុលលាងដៃអោយបានញឹកញាប់។
ត្រូវនៅអោយឆ្ងាយពីគ្នា - នៅអោយឆ្ងាយ៦ហ្វីត។
ត្រូវនៅផ្ទះហើយនៅដាច់ដោយឡែកពីគេ បើអ្នកមិនស្រួលខ្លួន។
ត្រូវទៅធ្វើតេស្តមើល COVID-19 បើអ្នកមិនស្រួលខ្លួន។

## សំណួររបស់អ្នកដែលបានឆ្លើយហើយ/ប្រធានបទ

1. តើមានតេស្តអ្វីខ្លះដើម្បីមើល COVID-19? តើតេស្តនោះមានអ្វីខុសពីគ្នា?
   ការធ្វើតេស្ត COVID -19 គឺមាន២យ៉ាង។

ការធ្វើតេស្តមើសកម្មរបស់មេរោគ: រកមើល SARS CoV-2, វីរុសដែលធ្វើអោយកើតCOVID-19

- ការធ្វើតេស្ត, ភាគច្រើនគេហៅថាតេស្ត PCR, គឺបានរចនាឡើងដើម្បីចាប់បានវីរុសដែលបង្ករោគ COVID-19។
- គោលបំណងនៃការធ្វើតេស្តនេះគឺដើម្បីវិនិច្ឆ័យ COVID-19 នៅក្នុងអ្នកជំងឺ។
- ការធ្វើតេស្តនេះអាចធ្វើឡើងដោយមានវិធីផ្សេងៗ, ដូចជាកំហាក, តម្បារបំពង់កឬតាមច្រមុះនិងបំពង់ក (គឺជាការតម្បារចូលទៅតាមច្រមុះហើយចូលទៅបំពង់កខាងក្រោយ).
- កាបរធ្វើតេស្តវិជ្ជមានមានន័យថាបុគ្គលនោះមាន COVID-19?
- លទ្ធផលអវិជ្ជមានមានន័យថាអត់បានរកឃើញវីរុសដែលធ្វើយអោយមាន COVID-19 នៅក្នុងកំហាកនោះទេ, ហើយមានន័យថា រោគជំងឺថ្មីៗរបស់បុគ្គលនេះមិនមែនមកពី COVID-19 ទេ។. Hទោះយ៉ាងណា, នៅពេលដែលឆ្លង COVID-19ថ្មីៗនោះ, វាអាចថាមិនអាចចាប់វីរុសបានភាមៗនោះទេ។
- បុគ្គលទាំងអស់មិនចាំបាច់ទៅធ្វើតេស្តនេះទេ។ មានតែបុគ្គលណាដែលមានរោគសញ្ញា COVID-19 ចាំបាច់ត្រូវទៅធ្វើតេស្ត។
  - បើអ្នកមានរោគសញ្ញា COVID-19, ត្រូវទៅម៉េយ៉ូគ្លីនិកពាយព្យ (Northwest) កន្លែងប្រមូលកំហាកមើល COVID-19 នៅ 4111 US-52 North, Rochester, MN ដើម្បីធ្វើតេស្ត។

ការតេស្ត PCR ដើម្បីមើល SARS CoV-2 បើឃើញថាវិជ្ជមានមានន័យថាបុគ្គលនោះមាន COVID-19។

ការធ្វើតេស្តដើម្បីរកមើលការឆ្លងថ្មីៗឬក៏ចាស់ៗ៖ ការរកឃើញអង្គបដិប្រាញរបស់ SARS CoV-2

- អាចហៅថាការធ្វើតេស្តសៀរៀល, ដោយយកឈាមរបស់បុគ្គលទៅរកមើលអង្គបដិប្រាញនៃ SARS CoV-2, ជាវីរុសដែលបង្ក COVID-19។

- អ្នកដែលបានឆ្លងហើយអង្គបដិប្រាណនឹងមានផលិតឡើងក្នុងខ្លួន, ដូចច្នេះហើយលទ្ធផលវិជ្ជមានពីតេស្តនេះបង្ហាញថាបុគ្គលនោះបានកើត COVID-19 ពីមុន។
- ទោះយ៉ាងណា, បើបុគ្គលនោះឆាប់ធ្វើតេស្តពេកមុននឹងរោគសញ្ញាបង្កឡើង, តេស្តអាចបង្ហាញថាអវិជ្ជមានដោយសារតែរៀងកាយអត់មានពេលគ្រប់គ្រាន់ដើម្បីបង្កាអង្គបដិប្រាណ។
- ទិន្នន័យបង្ហាញថាចំពោះអ្នកខ្លះវាត្រូវពេលពី៨ទៅ១១ថ្ងៃបានចាប់ផ្ដើមបង្កអង្គបដិប្រាណនៃ SARS CoV-2។
- ឥឡូវនេះមិនទាន់ដឹងនៅឡើយទេថាតើអង្គបដិប្រាណអាចការពារអ្នកណាបានអំពីការកើតវិរុសនេះម្ដងទៀតឬអង្គបដិប្រាណនេះនៃវិរុសនេះអាចជួយការពារអ្នកណាបានរយៈពេលប៉ុន្មាន។

  តេស្តសៀរៀលមើល SARS CoV-2 វិជ្ជមានមានន័យថាបុគ្គលនោះមាន COVID-19។

2. តើយើងអាចធ្វើយ៉ាងណាដើម្បីការពារចាស់ៗនិងអ្នកងាយរងគ្រោះនៅក្នុងសហគមន៍របស់យើងក្នុងពេលរាតត្បាតនេះ។

- មានធនធាននៅក្នុងសហគមន៍យើងនេះដើម្បីជួយចាស់ៗ។ បើអ្នកមានការព្រួយបារម្ភចំពោះចាស់ៗឬអ្នកដែលនៅដាច់ឆ្ងាយពីគេនៅក្នុងសហគមន៍យើង, Intercultural Mutual Assistance Association (IMAA) និង Family Service Rochester (FSR)ទាំងពីរមានការទទួលសុំណើរឆែកមើលពួកគាត់ "តាមការខលទៅបញ្ជាក់"។

  - FSR
    Phone: (507) 287-2010
    ម៉ោងធ្វើការៈ 8:00am – 5:00pm, ថ្ងៃច័ន្ទទៅថ្ងៃសុក្រ

3. តើខ្ញុំត្រូវធ្វើយ៉ាងណាបើខ្ញុំមិនស្រួលខ្លួន, ត្រូវការថ្នាំបន្ថែម, ឬត្រូវការជួបពេទ្យដោយសាររោគជំងឺចាស់ៗ?

- មិនថាអ្នកត្រូវការការថែរក្សាអ្វីនោះទេ — ការគាំទ្រអារម្មណ៍ក្នុងពេលរាតត្បាតនេះ, គ្រប់គ្រងបញ្ហារោគជំងឺរ៉ាំរ៉ៃ, យកថ្នាំបន្ថែម, ឬបារម្ភអំពីជំងឺថ្មីៗ — សូមតេទៅគ្រូពេទ្យប្រចាំខ្លួនរបស់អ្នក។ ក្រុមគ្រូពេទ្យរបស់អ្នកនៅទីនេះ, ដើម្បីរក្សាអ្នកតាមអ្នកត្រូវការ។

អ្នក ជាអ្នកនៅក្នុងសហគមន៍ គឺជាអ្នកនៅជួរមុខដើម្បីបញ្ឈប់COVID-19។
ដោយការលាងដៃ សំអាតនិងធ្វើអនាម័យ។ ដោយនៅឆ្ងាយពីគ្នា។ ដោយត្រូវនៅផ្ទះ។
យើងទាំងអស់គ្នានៅរួមជាមួយគ្នា។ យើងនិងបានជាសះស្បើយជាមួយគ្នា។

RHCP COVID-19 STAY HOME MINNESOTA